មជ្ឈមណ្ឌលឯកសារកម្ពុជា

# អង្គបុរេជំនុំជម្រះជំទាស់បណ្តឹងឧទ្ធរណ៍ពីរដែលតវ៉ានឹង ភាពត្រឹមត្រូវតាមច្បាប់នៃការសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្នរបស់ ខៀវ សំផន

*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

នៅក្នុងអង្គជំនុំជម្រះសាធារណៈមួយ ដែលធ្វើឡើងកាលពីពេលរសៀលនេះ អង្គបុរេជំនុំជម្រះបានសង្ខេបសេចក្តីសម្រេចដែលមានសែសិបមួយទំព័រ ដោយជំទាស់នឹងបណ្តឹងឧទ្ធរណ៍សំខាន់ៗពីររបស់ ខៀវ សំផន។ ជាលទ្ធផល ខៀវ សំផន ត្រូវបន្តឃុំខ្លួនរហូតដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

ជាសរុប អង្គបុរេជំនុំជម្រះបានសម្រេចចេញដីកាពីរនេះដោយផ្អែកលើមូលដ្ឋានដែលថា ដីកាទាំងនេះមិនមានជាប់ពាក់ព័ន្ធនឹងកំហុសនីតិវិធីឡើយ ។ ដីកានេះមានមូលហេតុច្បាស់លាស់ និងត្រឹមត្រូវដែលជឿជាក់ថា ខៀវ សំផន បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ពិតប្រាកដមែន ។ ដូច្នេះ ការឃុំខ្លួនគឺជាវិធីសាស្រ្តដ៏សំខាន់ក្នុងការធានាពីសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ហើយសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានយ៉ាងត្រឹមត្រូវ ។

ខៀវ សំផន ប្រធានប្រមុខរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៧ ហើយត្រូវបានឃុំខ្លួនចាប់តាំងពីពេលនោះមក ។ ក្រោយពីការស៊ើបអង្កេតថ្មីៗនេះ ខៀវ សំផន ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។

## ដីកាជំទាស់នឹងសំណើដោះលែងឲ្យនៅក្រៅឃុំ

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាជំទាស់នឹងសំណើដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំ ។ មេធាវីរបស់ ខៀវ សំផន បានប្តឹងឧទ្ធរណ៍នឹងដីកានេះ

ដោយផ្អែកលើមូលដ្ឋានកំហុសនីតិវិធី ។ មេធាវី ខៀវ សំផន បានអះអាងថា ដោយសារតែការពន្យាពេលឃុំខ្លួនមានរយៈពេលយូរ និងដោយសារតែឯកសារខ្លះនៅក្នុងសំណុំរឿងមិនទាន់បានបកប្រែទៅជាភាសាបារាំងដែលជាភាសាកំណើតរបស់មេធាវីអន្តរជាតិរបស់ ខៀវ សំផន ដូច្នេះដំណើរការនីតិវិធីមិនមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ហើយការឃុំខ្លួនគឺរំលោភទៅលើច្បាប់ ។ ជាលទ្ធផលនៃបញ្ហានីតិវិធីទាំងអស់នេះ មេធាវីការពារក្តីអះអាងថា ចៅក្រមអង្គបុរេជំនុំជម្រះមិនអាចរៀបចំឲ្យមានការឃុំខ្លួនឲ្យសមស្របតាមផ្លូវច្បាប់បានទេ ។ ឧទាហរណ៍ មេធាវីអន្តរជាតិរបស់ ខៀវ សំផន បានបដិសេធមិនបង្ហាញខ្លួននៅក្នុងអង្គសវនាការដោយសារតែឯកសារសំខាន់ៗមិនមានជាភាសាបារាំង ។ អង្គបុរេជំនុំជម្រះបានសម្រេចថា គ្មានការកំណត់សម្គាល់ឃើញពីកំហុសនីតិវិធីដែលកើតមាននៅក្នុងកិច្ចការរបស់សហចៅក្រមស៊ើបអង្កេតឡើយ ។

អង្គបុរេជំនុំជម្រះបានពិនិត្យមើលឡើងវិញនូវភាពចាំបាច់នៃការបន្តឃុំខ្លួន ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញថា ការបន្តឃុំខ្លួនបណ្តោះអាសន្នរបស់ ខៀវ សំផន ពិតជា«វិធីសាស្ត្រដ៏សំខាន់មួយក្នុងការការពារកុំឲ្យមានការគាបសង្កត់មកលើសាក្សី និងជនរងគ្រោះ» ដោយផ្អែកលើមូលដ្ឋានមួយដែល ខៀវ សំផន បាននិយាយកាលពីឆ្នាំ២០០២ មានចុះនៅក្នុងអត្ថបទមួយថា «ការសងសឹក»នឹងអាចកើតមានឡើង ប្រសិនបើតុលាការរបស់អង្គការសហប្រជាជាតិចង់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ អង្គបុរេជំនុំជម្រះបាននិយាយថា អត្ថបទនេះគឺជាភស្តុតាងមួយដែលមានលក្ខណៈខ្វះខាតនៅឡើយក្នុងការជឿថា ខៀវ សំផន អាចនឹងជ្រៀតជ្រែកជាមួយនឹងសាក្សី ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានយល់ស្របជាមួយនឹងសហចៅក្រមស៊ើបអង្កេតថា ការបន្តឃុំខ្លួនបណ្តោះអាសន្ន ខៀវ សំផន ពិតជា«វិធីសាស្ត្រសំខាន់ក្នុងការការពារសុវត្ថិភាពឲ្យជនជាប់ចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ» ។ ទាក់ទិននឹងសុវត្ថិភាព ខៀវ សំផន អង្គបុរេជំនុំជម្រះបានលើកហេតុផលថា ដំណើរការនីតិវិធីរបស់ អ.វ.ត.ក បានបង្កឲ្យមាន«ការកើតឡើងវិញនូវភាពអន្ទះអន្ទែងរបស់ជនរងគ្រោះដែលទទួលរងបញ្ហាតានតឹងផ្លូវចិត្ត» ដូច្នេះការដោះលែង ខៀវ សំផន ឲ្យនៅក្រៅឃុំ អាច«ជម្រុញឲ្យមានអំពើហិង្សាកើតឡើងចំពោះ ខៀវ សំផន បាន» ។ ទាក់ទិននឹងសណ្តាប់ធ្នាប់សាធារណៈ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ពីការរីករាលដាលនូវបញ្ហាតានតឹងផ្លូវចិត្ត ដែលកើតមានឡើងចំពោះប្រជាជនរស់នៅក្នុងរបបខ្មែរក្រហម និងពី«បរិបទដ៏ទ្រុឌទ្រោម នៃសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ» ។

ជាមួយគ្នានេះ មេធាវី ខៀវ សំផន បានអះអាងថា ការបន្តឃុំខ្លួនបានដាក់ទម្ងន់ទោសមកលើបញ្ហាសុខភាពទ្រុឌទ្រោមរបស់ ខៀវ សំផន ។ អង្គបុរេជំនុំជម្រះបានផ្អែកលើយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលសម្រេចថា ការដោះលែងឲ្យនៅក្រៅឃុំដោយផ្អែកលើបញ្ហាសុខភាពអាចនឹងមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ លុះត្រាតែមានភស្តុតាងបញ្ជាក់ថា លក្ខខណ្ឌសុខភាពរបស់ជនជាប់ឃុំមិនអាច«ទ្រាំទ្របាននឹងការឃុំខ្លួន»តែប៉ុណ្ណោះ ។

## ដីកាពន្យាពេលឃុំខ្លួនបណ្តោះអាសន្ន

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាពន្យាពេលឃុំខ្លួនបណ្តោះអាសន្នរបស់ ខៀវ សំផន ក្នុងរយៈពេលមួយឆ្នាំបន្ថែមទៀត ។

មេធាវីរបស់ ខៀវ សំផន បានអះអាងថា សេចក្តីសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត គួរតែត្រូវបានពន្យាពេលរហូតដល់មានការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មួយស្តីពីសេចក្តីបង្គាប់ឲ្យមានការបកប្រែឯកសារសំខាន់ៗជាមុនសិន ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍មិនស្ថិតនៅក្នុងដំណើរការនីតិវិធីទេ ហេតុដូច្នេះអង្គបុរេជំនុំជម្រះមិនយល់ថាបណ្តឹងឧទ្ធរណ៍អាចបង្កឲ្យមានភាពមិនទៀងទាត់នៃដំណើរការនីតិវិធីឡើយ ។

យោងតាមវិធាន៦៣នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតអាចមានឆន្ទានុសិទ្ធិក្នុងការចេញដីកាឃុំខ្លួនបណ្តោះអាសន្នបានលុះត្រាតែ«មានមូលហេតុច្បាស់លាស់ និងត្រឹមត្រូវដែលជឿជាក់ថាជនជាប់ចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម» ។ អង្គបុរេជំនុំជម្រះបានពិនិត្យមើលសំណុំរឿង ហើយបានពេញចិត្តនឹងហេតុផលច្បាស់លាស់ និងត្រឹមត្រូវ ដែលបានរកឃើញដោយសហចៅក្រមស៊ើបអង្កេត» ។ ឧទាហរណ៍ មានភស្តុតាងមួយបានអះអាងថា ខៀវ សំផន បានបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលជាច្រើនដែលធ្វើការផ្សព្វផ្សាយមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងបានថ្លែងសន្ទរកថាជាច្រើនស្តីពី«ការកម្ទេច»ខ្មាំង និងបានចូលរួមអង្គប្រជុំស្តីពីការសម្លាប់ជនក្បត់ ។ បន្ថែមលើនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ក្រោយពីដីកាសម្រេចបន្តឃុំខ្លួនមក គ្មានភស្តុតាងដាក់បន្ទុកត្រូវបានបន្ថែមចូលទៅក្នុងសំណុំរឿងឡើយ ។

ដូចគ្នានឹងសេចក្តីសម្រេចខាងលើ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញថា ការបន្តឃុំខ្លួនពិតជាវិធីសាស្ត្រដ៏សំខាន់មួយ ដើម្បីការពារសុវត្ថិភាពឲ្យ ខៀវ សំផន និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ។